ការិយាល័យកណ្តាល

# សេចក្តីជូនដំណឹង

## ស្តីពី

## លទ្ធផលនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៣ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិក និងសាធារណជន មេត្តាទទួលជ្រាបថា កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៣ របស់ធនាគារ អេស៊ីលីដា បានប្រព្រឹត្តទៅនៅ**ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣** វេលាម៉ោង **១៤:០០នាទី** នៅធនាគារ អេស៊ីលីដា ការិយាល័យកណ្តាល មានទីតាំងស្ថិតនៅ អគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានកូរ៉ុមចំនួន **៨៣,៧១** ភាគរយ និងភាគហ៊ុនិកចូលរួមចំនួន **១៣០** នាក់ ស្មើនឹង **៣៦២.៥៨៦.១៣៨** ភាគហ៊ុន។

ភាគហ៊ុនិកបានពិនិត្យ ពិភាក្សា និងអនុម័តដូចខាងក្រោម៖

១. អនុម័តការបែងចែកភាគលាភជាសាច់ប្រាក់ចំនួន**៤០ភាគរយ** នៃប្រាក់ចំណេញក្នុងឆ្នាំ២០២២ ដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ចំនួន**៧៤២.៧៦៤.៦៧០.០០០រៀល** ស្មើនឹង**២៩៧.១០៥.៨៦៤.៩៨៧,៥៨រៀល** ក្នុងអត្រា**៦៨៥,៨៩៨៥**រៀល ក្នុង១ភាគហ៊ុន និងរក្សាប្រាក់ចំណេញនៅសល់ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុករបស់ធនាគារ អេស៊ីលីដា។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩៣ ភាគរយ។***

២. អនុម័តគោលការណ៍ភាគលាភ។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩៣ ភាគរយ។***

៣. អនុម័តការតែងតាំង **លោក ឆាយ សឿន** ជាអភិបាលធនាគារ អេស៊ីលីដា សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩៣ ភាគរយ។***

៤. អនុម័តការតែងតាំង **បណ្ឌិត អ៊ិន ចាន់នី** ជាអភិបាលធនាគារ អេស៊ីលីដា សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩៣ ភាគរយ។***

៥. អនុម័តការតែងតាំង **លោក វ៉ាន់ ស៊ូអៀង** ជាអភិបាលឯករាជ្យ នៅធនាគារ អេស៊ីលីដា រហូតដល់ថ្ងៃចូលនិវត្តន៍ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩២ ភាគរយ។***

៦. អនុម័តការជ្រើសរើស PricewaterhouseCoopers (“PwC”) ជាសវនករឯករាជ្យរបស់ធនាគារ អេស៊ីលីដា សម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២៤។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៩២ ភាគរយ។***

៧ អនុម័តការដំឡើងប្រាក់បៀវត្សជូនប្រធានក្រុមប្រឹក្សាភិបាលដូចខាងក្រោម៖

- ដំឡើងប្រាក់បៀវត្សជូន **លោក ឆាយ សឿន** ប្រធានក្រុមប្រឹក្សាភិបាល ដោយទទួលបានចំណាត់ថ្នាក់ “A+” ដែលមានប្រសិទ្ធភាពអនុវត្តប្រតិសកម្ម ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣។
- បូកបន្ថែមអត្រាអតិផរណាប្រចាំឆ្នាំ២០២២ ចំនួន ៣% (បីភាគរយ) លើប្រាក់បៀវត្សរបស់ប្រធានក្រុមប្រឹក្សាភិបាល ដែលមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៨៩ ភាគរយ។***

៨. អនុម័តកម្រៃសេវា សម្រាប់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ស្របតាមអត្រាអតិផរណាប្រចាំឆ្នាំ២០២២ ចំនួន ៣% (បីភាគរយ) ។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៨៩ ភាគរយ។***


អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

៩. អនុម័តកាលបរិច្ឆេទកំណត់ទុកនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ សម្រាប់កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៨៦ ភាគរយ។***

១០. អនុម័តការធ្វើវិសោធនកម្មលើមាត្រា៨ (“ការទិញភាគហ៊ុន”) ឧបសម្ព័ន្ធ១ (“សមាសភាពនៃក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា”) ឧបសម្ព័ន្ធ៣ (“បញ្ជីឈ្មោះភាគហ៊ុនិកសាធារណៈរបស់ ធនាគារ អេស៊ីលីដា”) និងឧបសម្ព័ន្ធ៤ (“បញ្ជីឈ្មោះភាគហ៊ុនិកដែលធ្វើនិយ័តកម្មពីក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី”) នៃលក្ខន្តិកៈ ធនាគារ អេស៊ីលីដា។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,៨២ ភាគរយ៕***

ថ្ងៃព្រហស្បតិ៍ ៨កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**